# ទុក្ករកម្មនៃព្យាការី យ៉ូសែប ស្ម៊ីធ

### អ្នកប្រឆាំងនឹងព្យាការី និងសាសនាចក្រ

ត្រឹមខែ មិថុនា ឆ្នាំ ១៨៤៤ ភាពអនាមិកប្រឆាំងនឹងសាសនាចក្របានមានភាពតានតឹងជាខ្លាំង ។ ប្រជាជនខ្លះនៅក្នុងរដ្ឋអិលលីណយ បានពិភាក្សាពីការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ ខណៈអ្នកផ្សេងទៀតបានគ្រោងសម្លាប់ព្យាការី ។ អ្នកខ្លះដែលបានរួមគំនិតក្បត់នឹងព្យាការី និងសាសនាចក្រគឺជាអតីតសមាជិកនៃសាសនាចក្រដែលបានក្បត់សាសនា ។ នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៨៤៤ វិល្លៀម ឡ ដែលបានបម្រើជាទីប្រឹក្សាទីពីរនៃគណៈប្រធានទីមួយ និងអ្នកក្បត់សាសនាផ្សេងទៀតបានបោះពុម្ពលេខកាសែតទីមួយដែលហៅថា *Nauvoo Expositor* ។ ដោយមានបំណងចង់ផុតដល់សាធារណជនឲ្យប្រឆាំងនឹងព្យាការី និងសាសនាចក្រ បុរសទាំងនេះបានប្រើកាសែតដើម្បីនិយាយបង្ខូចដល់ យ៉ូសែប ស្ម៊ីធ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀត ។ យ៉ូសែប ស្ម៊ីធ ដែលធ្វើជាអភិបាលទីក្រុងណៅវូ ហើយក្រុមប្រឹក្សាក្រុងណៅវូភាគច្រើនបានទទួលស្គាល់ថា កាសែតអុជអាលនេះនឹងនាំទៅរកអំពើហិង្សាឥតសណ្ដាប់ធ្នាប់ប្រឆាំងនឹងក្រុងនេះ ។ ពួកគេបានប្រកាសថាក្រុមកាសែតនេះជាភាពសៅហ្មងដល់សាធារណជន និងបានបញ្ជាឲ្យកាសែត *Nauvoo Expositor* ត្រូវតែបំផ្លាញចោល ។

### យ៉ូសែប និងហៃរ៉ុម ត្រូវបានចោទប្រកាន់ដោយខុសឆ្គង

« ជាលទ្ធផលនៃ [ ការបំផ្លិចបំផ្លាញដល់ *Nauvoo Expositor* ] ដោយអភិបាលក្រុង និងក្រុមប្រឹក្សាក្រុង អ្នកមានសិទ្ធិអំណាចរដ្ឋអិលលីណយបានធ្វើឲ្យមានការចោទប្រកាន់ដែលមិនមានភាពពិតអំពីកុប្បកម្មប្រឆាំងនឹងព្យាការី បងប្រុសរបស់លោក ហៃរ៉ុម និងមន្ត្រីរាជការក្រុងណៅវូផ្សេងទៀត ។ អភិបាលរដ្ឋអិលលីណយ ថូម៉ាស ហ្វត បានបញ្ជាឲ្យពួកបុរសនោះទៅតុលាការនៅទីក្រុងកាតធេច រដ្ឋអិលលីណយ ជាទីតាំងស្រុក និងបានសន្យាថានឹងការពារពួកគេ ។ យ៉ូសែប បានដឹងថា ប្រសិនបើលោកទៅទីក្រុងកាតធេច នោះជីវិតលោកនឹងស្ថិតនៅក្នុងគ្រោះថ្នាក់ដ៏ធំដែលមកពីពួកមនុស្សកំណាច ដែលបានគំរាមកំហែងលោក ។

« ដោយជឿថា ហ្វូងមនុស្សកំណាចចង់បានតែពួកលោក នោះយ៉ូសែប និងហៃរ៉ុម បានសម្រេចចិត្តចាកចេញទៅភាគខាងលិចដើម្បីការពារជីវិតរបស់ពួកលោក ។ នៅថ្ងៃទី ២៣ ខែ មិថុនា ពួកលោកបានឆ្លងទន្លេមិស៊ីស៊ីពី ប៉ុន្តែក្រោយមកនៅថ្ងៃនោះ បងប្អូនប្រុសមកពីទីក្រុងណៅវូបានរកឃើញព្យាការី ហើយបានប្រាប់លោកថា ពួកទាហានចង់លុកលុយក្រុងប្រសិនបើលោកមិនព្រមចុះចាញ់នឹងពួកអ្នកមានសិទ្ធិអំណាចនៅក្នុងទីក្រុងកាតធេចទេនោះ ។ ការណ៍នេះធ្វើឲ្យព្យាការីយល់ព្រមធ្វើតាម ដោយសង្ឃឹមថានឹងធ្វើឲ្យស្ងប់ចិត្តដល់ទាំងពួកមន្ត្រីរដ្ឋាភិបាល និងពួកមនុស្សកំណាច ។ នៅថ្ងៃទី ២៤ ខែ មិថុនា យ៉ូសែប និងហៃរ៉ុម ស្ម៊ីធ បានលាដល់គ្រួសាររបស់ពួកលោក និងចេញដំណើរទៅជាមួយនឹងពួកមន្ត្រីក្រុងណៅវូទៅកាន់ទីក្រុងកាតធេច ដោយស្ម័គ្រចិត្តចុះចាញ់នឹងមន្ត្រីស្រុកនៅក្នុងទីក្រុងកាតធេចនៅថ្ងៃបន្ទាប់ ។ បន្ទាប់ពីបងប្អូនប្រុសត្រូវបានគេដោះលែងដោយដាក់តម្កល់ប្រាក់សម្រាប់ការចោទប្រកាន់លើកទីមួយ នោះពួកគេត្រូវបានចោទប្រកាន់ដោយខុសឆ្គងពីបទក្បត់នឹងរដ្ឋអិលលីណយ ត្រូវបានគេចាប់ ហើយដាក់គុកនៅក្នុងទីក្រុងកាតធេចដើម្បីរង់ចាំដល់ការកាត់ក្ដី ។ អែលឌើរ យ៉ូហាន ថេលើរ និងវិលឡឺឌ រីឆាដ ជាសមាជិកនៃពួកដប់ពីរនាក់ដែលពេលនោះមិនបានបម្រើបេសកកម្ម ស្ម័គ្រចិត្តទៅតាមពួកលោក » ( *ការបង្រៀនទាំងឡាយរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ៥២៩–៣០ ) ។

### ទុក្ករកម្មនៅគុកកាតធេច

អំឡុងថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ អ្នកមកលេងម្នាក់បានឲ្យកាំភ្លើងមួយដល់យ៉ូសែប ។ នៅពេលពួកមនុស្សកំណាចបានព្យាយាមចូលទៅក្នុងបន្ទប់ដែលព្យាការី និងបុរសផ្សេងទៀតដែលត្រូវគេចាប់នោះ ហៃរ៉ុម ត្រូវបានគេបាញ់ស្លាប់ ពេលព្យាយាមការពារដល់គ្រប់គ្នានៅក្នុងបន្ទប់នោះ ។ យ៉ូសែប បានលោតទៅទ្វារ ហើយឈោងទៅគ្រោងទ្វារដើម្បីបាញ់តបទៅកាន់ខ្មាន់កាំភ្លើងដែលនៅក្នុងសាល ។ មានតែសមាជិកបីនាក់ក្នុងចំណោមប្រាំមួយនាក់ប៉ុណ្ណោះដែលបានបាញ់ ធ្វើឲ្យសមាជិកបីបួននាក់នៃពួកមនុស្សកំណាចរងរបួសខ្លះ ។ ពេលនោះពួកមនុស្សកំណាចបានរុញកាំភ្លើងរបស់គេចូលពាក់កណ្ដាលទ្វារដែលបិទ ហើយយ៉ូហាន ថេលើរ បានព្យាយាមវាយបំពង់កាំភ្លើងរបស់ពួកគេឲ្យដកថយវិញដោយដងឈើមួយ ។

នៅពេលចលាចលនៅឯទ្វារនោះបានកើនឡើង នោះយ៉ូហាន ថេលើរ បានព្យាយាមរត់គេចដោយផ្លោះតាមបង្អួចបន្ទប់ ។ នៅពេលលោកចង់លោតចេញពីបង្អួច លោកត្រូវបានគេបាញ់ចំភ្លៅដែលបាញ់ពីមាត់ទ្វារ ហើយក៏ត្រូវគេបាញ់ចំពីខាងក្រៅផងដែរ ។ លោកបានធ្លាក់ទៅនឹងដី ហើយខណៈដែលខំវារទៅក្រោមគ្រែក្បែរបង្អួចនោះ លោកត្រូវបានគេបាញ់យ៉ាងដំណំបីគ្រាប់ទៀត ។ ទន្ទឹមនឹងគ្នានោះ នៅពេលកាំភ្លើងជាច្រើនបានបាញ់ចូលមកតាមមាត់ទ្វារ នោះវិលឡឺឌ រីឆាដ បានចាប់ផ្ដើមគត់វាំងនឹងពួកគេដោយឈើច្រត់មួយ ។

ពេលនោះ យ៉ូសែប ស្ម៊ីធ បានសម្រេចចិត្តព្យាយាមរត់គេចចេញតាមបង្អួចដដែលនោះ ។ នៅពេលវិលឡឺឌ រីឆាដ បានបន្តវាយប្ដួតពួកមនុស្សកំណាចនៅឯមាត់ទ្វារ នោះព្យាការីបានលោតទៅបង្អួចដែលបើករួចនោះ ។ នៅពេលលោកបានធ្វើដូច្នោះ មានគ្រាប់កាំភ្លើងជាច្រើនទាំងពីខាងក្នុង និងខាងក្រៅគុកបានបាញ់ចំលោក ។ លោកបានធ្លាក់ចេញពីបង្អួចដោយស្រែកថា « ឱ ព្រះអម្ចាស់ ជាព្រះខ្ញុំអើយ » ហើយក៏បានធ្លាក់ដល់ដីខាងក្រោមទៅ ។ សមាជិកពួកមនុស្សកំណាចខ្លះដែលនៅខាងក្នុងគុក បានរត់ចេញទៅក្រៅដើម្បីបញ្ជាក់ថា យ៉ូសែប បានស្លាប់មែន ។ ទោះបីជាគ្មានសមាជិកសាសនាចក្រណាមួយនៅតាមផ្លូវទៅទីក្រុងកាតធេច ក៏មានមនុស្សម្នាក់ស្រែកថា « ពួកមរមនមកហើយ » ហើយហ្វូងមនុស្សកំណាចទាំងមូលក៏រត់គេចចេញអស់ទៅ ។

### ការគោរពដល់ព្យាការី យ៉ូសែប ស្ម៊ីធ

អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ ៖



« មនុស្សដែលបានស្គាល់ យ៉ូសែប ច្បាស់បំផុត ហើយបានឈរក្បែរលោកបំផុតនៅក្នុងការដឹកនាំសាសនាចក្រ ស្រឡាញ់ និងបានគាំទ្រលោកជាព្យាការី ។ បងប្រុសរបស់លោក ហៃរ៉ុម បានសុខចិត្តស្លាប់នៅក្បែរលោក ។ យ៉ូហាន ថេលើរ ក៏នៅជាមួយនឹងលោកដែរ នៅពេលលោកត្រូវបានគេសម្លាប់នោះ មានប្រសាសន៍ ៖ ‹ ខ្ញុំថ្លែងទីបន្ទាល់ចំពោះមុខព្រះ ទេវតា និងមនុស្សទាំងឡាយថា គាត់គឺជាបុរសដ៏ល្អ មានកិត្តិយសប្រកបដោយគុណធម៌ម្នាក់ . . . — ថាលក្ខណៈឯកជន និងទូទៅរបស់លោកគ្មានមន្ទិលសង្ស័យនោះទេ — ហើយថាលោកបានរស់នៅ និង ស្លាប់ក្នុងនាមជាបុរសម្នាក់នៃព្រះ › ( *The Gospel Kingdom* [ ឆ្នាំ ១៩៨៧ ] ទំព័រ ៣៥៥ ; សូមមើលផងដែរ គ និង ស ១៣៥:៣ ) ។ ព្រិកហាំ យ៉ង់ បានប្រកាស ៖ ‹ ខ្ញុំមិនគិតថាបុរសដែលរស់នៅលើផែនដីបានស្គាល់ [ យ៉ូសែប ស្ម៊ីធ ] ប្រសើរជាងខ្ញុំស្គាល់លោកនោះទេ ហើយខ្ញុំនិយាយដោយម៉ឺងម៉ាត់ថា លើកលែងតែព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ នោះគ្មានមនុស្សណាម្នាក់ធ្លាប់បានរស់នៅ ឬនឹងរស់នៅលើផែនដីនេះប្រសើរជាងយ៉ូសែប ស្ម៊ីធ ឡើយ › [*Discourses of Brigham Young,* sel. John A. Widtsoe ( ឆ្នាំ ១៩៥៤ ) ទំព័រ ៤៥៩ ] » (« Joseph, the Man and the Prophet » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៧៣ ) ។

© ២០១៩ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។